ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ៤៣៨ ២៩/២០២៥ កបទ.សអ

# សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីកម្ពុជាថ្កោលទោសការឈ្លានពានរបស់ថៃ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមថ្កោលទោស យ៉ាងខ្លាំងក្លាបំផុតចំពោះការឈ្លានពានប្រដាប់អាវុធរបស់ប្រទេសថៃមកលើកម្ពុជា រួមមានការប្រើប្រាស់យន្តហោះចម្បាំង F-16 វាយប្រហារតាមអាកាសលើទីតាំងជាច្រើននៅតាមបណ្តាខេត្តនានាតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ សកម្មភាពបែបនេះ គឺជាការរំលោភលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា បំពានធម្មនុញ្ញអង្គការសហប្រជាជាតិ និងមិនគោរពទាំងធម្មនុញ្ញអាស៊ាន និងស្មារតីនៃសហគមន៍អាស៊ាន។

ការប្រើប្រាស់យន្តហោះចម្បាំង F-16 ក្នុងទឹកដីកម្ពុជា គឺជាការប្រើប្រាស់កម្លាំងមិនសមាមាត្រ និងមិនត្រឹមត្រូវយ៉ាងពិតប្រាកដ។ ការវាយប្រហារតាមអាកាសដែលធ្វើឡើងដោយយោធាថៃ រួមទាំងប្រតិបត្តិការដែលត្រូវបានរាយការណ៍ថា ចូលជ្រៅប្រមាណ ៨០-៩០គីឡូម៉ែត្រ ទៅក្នុងទឹកដីកម្ពុជា បានបណ្តាលឱ្យបាត់បង់ជីវិតជនស៊ីវិលជាច្រើន និងមានប្រជាជនជាង ៤០០,០០០នាក់ ត្រូវភៀសខ្លួន ព្រមទាំងបង្កការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ការវាយប្រហារទាំងនេះបានធ្វើឱ្យខូចខាត និងបំផ្លិចបំផ្លាញតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ រួមមានប្រាសាទព្រះវិហារ និងប្រាសាទផ្សេងទៀតដែលមានសារៈសំខាន់ផ្នែកវប្បធម៌ និងសាសនា ព្រមទាំងផ្ទះសម្បែងប្រជាពលរដ្ឋ សាលារៀន មន្ទីរពេទ្យ វត្តអារាម សណ្ឋាគារ កាស៊ីណូ ការិយាល័យរដ្ឋបាល ស្ពានជ័យជំនះ និងហេដ្ឋារចនាសម្ព័ន្ធស៊ីវិលសំខាន់ៗដទៃទៀត។ សកម្មភាពបែបនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងកាតព្វកិច្ចអន្តរជាតិ ក្នុងការការពារជនស៊ីវិល និងទ្រព្យសម្បត្តិវប្បធម៌។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អំពាវនាវដល់យោធាថៃឱ្យបញ្ឈប់ជាបន្ទាន់នូវការទម្លាក់គ្រាប់បែកពីលើអាកាស និងប្រតិបត្តិការយោធាណាមួយ ដែលបង្កហានិភ័យដល់ជនស៊ីវិល និងជំរុញឱ្យកងទ័ពថៃគោរពច្បាប់អន្តរជាតិ និងផ្តល់អាទិភាពលើការការពារជនស៊ីវិល និងគោលដៅស៊ីវិល។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

រាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួន និងឥតងាករេ ក្នុងការអនុវត្ត បទឈប់បាញ់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ព្រមទាំងទាមទារឱ្យប្រទេសថៃបញ្ឈប់ការប្រើប្រាស់កម្លាំង ក្នុងការកំណត់ព្រំដែន និងត្រឡប់ទៅរកមធ្យោបាយដោះស្រាយជម្លោះដោយសន្តិវិធី ស្របតាមគោលការណ៍ភាពជាអ្នកជិតខាងល្អ និងច្បាប់អន្តរជាតិ៕

ថ្ងៃចន្ទ ១០រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥